**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## រូបសញ្ញា និងត្រារបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារបន្ថែមនៃអនុសញ្ញា ស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



www.pheakdeylaw.com

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីរូបសញ្ញា និងត្រារបស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម (គ.ជ.ប.ទ)។

**មាត្រា២.-**

គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ត្រូវបានហៅកាត់ថា " គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម " ឬ " គ.ជ.ប.ទ " និងសរសេរជាអក្សរអង់គ្លេសថា National Committee Against Torture, Cruel Inhumanity, Degrading Treatment or Punishment ត្រូវបានហៅកាត់ថា " National Committee Against Torture " ឬ " NCAT " ។

## ជំពូកទី២

## រូបសញ្ញា និងត្រា

**មាត្រា៣.-**

រូបសញ្ញារបស់ គ.ជ.ប.ទ មានលក្ខណៈ និងអត្ថន័យ ដូចខាងក្រោម ៖

- កួរស្រូវពណ៌មាស ជានិមិត្តរូបនៃការអភិវឌ្ឍលើគ្រប់វិស័យ សន្តិភាព សុភមង្គល សម្បូរុងរឿង ប្រជាធិបតេយ្យ និងជាតិកម្ពុជា
- ស្លឹកអូលីវ ពណ៌បៃតង ជានិមិត្តរូប នៃការរីកលូតលាស់របស់ពិភពលោក
- រង្វង់មូលហ៊ុំព័ទ្ធរាងជាស្នែងក្របី ដោយកួរស្រូវផ្នែកខាងឆ្វេង និងស្លឹកអូលីវផ្នែកខាងស្តាំ តភ្ជាប់គ្នាផ្នែកខាងក្រោម ដោយបូពណ៌ខៀវ អមសងខាងដោយពណ៌ក្រហមដែលមានខ្នាតសមាមាត្រស្មើនឹង២ភាគ៥នៃទទឹងបូទាំងមូល និងនៅផ្ទៃក្នុងបូ សរសេរអក្សរកាត់ថា " **គ.ជ.ប.ទ** " ជានិមិត្តរូប



www.pheakdeylaw.com

នៃកិច្ចសហប្រតិបត្តិការល្អ រវាងស្ថាប័នជាតិនិងអន្តរជាតិ ប្រឆាំងទារុណកម្ម ស្របតាមច្បាប់ជាតិ និងវិធាននានារបស់អង្គការសហប្រជាជាតិ ដែលកម្ពុជាជារដ្ឋភាគី

- ផ្ទៃក្នុងនៃវណ្ឌវង្វង់មូលជុំវិញ មានពណ៌ផ្ទៃមេឃអមដោយវណ្ឌឆ្នូតពណ៌ក្រហម តំណាងឲ្យសិទ្ធិ សេរីភាព សន្តិភាព និងសេចក្ដីថ្លៃថ្នូរ
- ផ្នែកខាងលើនៃវណ្ឌវង្វង់មូលជុំវិញ សរសេរជាភាសាខ្មែរថា" **គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម** " និងផ្នែកខាងក្រោមសរសេរជាភាសាអង់គ្លេសថា " NATIONAL COMMITTEE AGAINST TORTURE " ភ្ជាប់ដោយក្បាច់ផ្កាចន្ទន៍ពណ៌មាស ជានិមិត្តរូបនៃកិច្ចសហប្រតិបត្តិការល្អក្នុងការអនុវត្តការងារ
- ផ្ទៃកណ្ដាលរង្វង់មូលមានផ្ទៃពណ៌ស តំណាងឲ្យយុត្តិធម៌ និងមានរូបមនុស្សក្នុងសម្លៀកបំពាក់ពណ៌ខ្មៅខ្មៅ អង្គុយបញ្ឈរជង្គង់យកដៃឱបក្បាល តំណាងឲ្យជនដែលត្រូវបានដកហូតសេរីភាព
- រូបដៃកាន់ដំបងក្នុងរង្វង់នៃសញ្ញាបម្រាម តំណាងឲ្យការហាមឃាត់និងប្រឆាំងដាច់ខាតចំពោះអំពើទារុណកម្មគ្រប់ទម្រង់បង្កឡើងដោយមន្ត្រីសាធារណៈ ឬជនផ្សេងទៀតដែលបំពេញតួនាទីជាផ្លូវការ ។

រូបសញ្ញារបស់ គ.ជ.ប.ទ ភ្ជាប់ជាឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ ។

**មាត្រា៤.-**

គ.ជ.ប.ទ មានត្រារាងជារង្វង់មូល និងទំហំ៣៥មីលីម៉ែត្រ រំលេចដោយរូបប្រាសាទកំពូលបីនៅចំកណ្ដាល។ ប្របតាមវណ្ឌផ្នែកខាងលើប្រាសាទកំពូលបី ឆ្លាក់អក្សរថា " **ព្រះរាជាណាចក្រកម្ពុជា** " និងផ្នែកខាងក្រោមឆ្លាក់អក្សរថា " **គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម** " ភ្ជាប់ដោយផ្កាចន្ទន៍ ។

គំរូត្រា ភ្ជាប់ជាឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ



www.pheakdeylaw.com

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

**ឧបសម្ព័ន្ធ១** នៃអនុក្រឹត្យលេខ..៤៧.....អនក្រ.បក ចុះថ្ងៃទី...២៧.....ខែ.កុម្ភៈ...ឆ្នាំ២០១៨

រូបសញ្ញា របស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ
អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
(គ.ជ.ប.ទ)

www.pheakdeylaw.com

**ឧបសម្ព័ន្ធ២** នៃអនុក្រឹត្យលេខ..៤៧......អនក្រ.បក ចុះថ្ងៃទី..២៧.....ខែ..កុម្ភៈ....ឆ្នាំ២០១៨

គំរូត្រា របស់គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ
អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
(គ.ជ.ប.ទ)

